| | | | | |
|---|---|---|---|---|
| ១២៤ | លោក ញ៉ៀក ចំរើន | អធិការ ក្រុមអធិការកិច្ច | សាលាខេត្តបន្ទាយមានជ័យ | - |
| ១២៥ | លោក ស៊ុក សារ៉ាដ | អធិការ ក្រុមអធិការកិច្ច | សាលាក្រុងកែប | - |
| ១២៦ | លោក កុយ ជៀចឌីនសៃ | នាយរងខុទ្ទកាល័យ | សាលាខេត្តរតនគិរី | - |
| ១២៧ | លោក ឡាំ សំបូរ | នាយរងក្រុមហិរញ្ញវត្ថុ | សាលាខេត្តបន្ទាយមានជ័យ | - |
| ១២៨ | លោក អ៊ឹម គិរម្យ | នាយរងក្រុមហិរញ្ញវត្ថុ | សាលាខេត្តកំពង់ឆ្នាំង | - |
| ១២៩ | លោក អេង ណៃ | នាយរងក្រុមហិរញ្ញវត្ថុ | សាលាខេត្តពោធិសាត់ | - |
| ១៣០ | លោក ខៀវ យ៉ាប | នាយការិយាល័យ | សាលាខេត្តព្រៃវែង | - |
| ១៣១ | លោក អន មង្គល | អនុប្រធាននាយកដ្ឋាន | នាយកដ្ឋានរដ្ឋបាលទូទៅ | - |
| ១៣២ | លោក ឆេស ម៉ាញ | ជំនួយការអភិបាលខេត្ត | សាលាខេត្តបាត់ដំបង | |

មាត្រា២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

## ២- សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០០

### សេចក្តីសំរេច លេខ ៥២ សសរ

### ស្តីពី

### ការបង្កើតគណៈកម្មាធិការជាតិដើម្បីត្រៀមលក្ខណៈសម្បត្តិ ទទួលរៀបចំកិច្ចប្រជុំកំពូលអាស៊ាន ឆ្នាំ ២០០២

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

ប្រការ ១ : បង្កើតគណៈកម្មាធិការជាតិមួយដើម្បីត្រៀមលក្ខណៈ សម្បត្តិទទួល រៀបចំកិច្ចប្រជុំកំពូលអាស៊ាន ឆ្នាំ២០០២ ដែលមានសមាសភាពដូចខាងក្រោមនេះ :

| | | |
|---|---|---|
| ១-ឯកឧត្តម ហោ ណាំហុង | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ជាប្រធាន |
| ២-ឯកឧត្តម សុខ អាន | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាអនុប្រធាន |
| ៣-ឯកឧត្តម គាត ឈន់ | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៤-ឯកឧត្តម ចម ប្រសិទ្ធ | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ៥-ឯកឧត្តម ឯម សំអាន | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៦-ឯកឧត្តម មិន ឌិន | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ | ជាសមាជិក |

ប្រការ ២ : គណៈកម្មាធិការជាតិរៀបចំកិច្ចប្រជុំនេះ ប្រើប្រាស់លេខាធិការដ្ឋានអាស៊ានជាតិ ជាសេនាធិការ ។

ប្រការ ៣ : គណៈកម្មាធិការជាតិរៀបចំកិច្ចប្រជុំនេះមានភារកិច្ចដូចតទៅ :

ក-រៀបចំកម្មវិធីនៃកិច្ចប្រជុំ និងពិធីការអោយបានសមស្រប

ខ-រៀបចំគំរោងថវិកាចំណាយក្នុងការរៀបចំកិច្ចប្រជុំនេះ រួចលើកសំណើសុំការសំរេចពីរាជរដ្ឋាភិបាល

គ-សំរបសំរួលរៀបចំការពារសន្តិសុខដល់គណៈប្រតិភូ និងសមាជិកអង្គប្រជុំអោយមានសុវត្ថិភាពល្អ

ឃ-ទទួលបន្ទុករៀបចំតាក់តែងសំដែងសិល្បៈបុរាណ ជូនគណៈប្រតិភូក្នុងលក្ខណៈក្របខ័ណ្ឌជាតិ និងភាគៈអន្តរជាតិ

ង-ជួយសំរបសំរួល និងចាត់ចែងលើការធ្វើដំណើរទស្សនាចរណ៍ដល់គណៈប្រតិភូក្រោយកិច្ចប្រជុំចប់ តាមកម្មវិធីដែលបានគ្រោងទុក ។

ច-ជួយសំរបសំរួលជាមួយប្រព័ន្ធឃោសនាជាតិ និងអន្តរជាតិ ដើម្បីធ្វើការផ្សព្វផ្សាយកិច្ចប្រជុំនេះ

ប្រការ ៤ : គណៈកម្មាធិការជាតិនេះ មានសិទ្ធិអញ្ជើញមន្ត្រីជំនាញនៃក្រសួង និងស្ថាប័នពាក់ព័ន្ធនានា មកចូលរួមប្រជុំដើម្បីពិភាក្សា និងដោះស្រាយការងារផ្សេងៗដែលចាំបាច់ ។

ប្រការ ៥ : គណៈកម្មាធិការនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការជំនាញផ្សេងទៀតតាមការចាំបាច់ ។

ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម ដែលមានឈ្មោះក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខានិងត្រា**

**ហ៊ុន សែន**

***

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០០

**សេចក្តីសំរេច លេខ ៥៣ សសរ**

**ស្តីពី**

**ការបង្កើតគណៈកម្មការអន្តរក្រសួង ទទួលបន្ទុកស្រាវជ្រាវ និងពិនិត្យច្បាប់សមុទ្រ ឆ្នាំ ១៩៨២** (UNCLOS 1982)

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

**សំរេច**

ប្រការ ១ : បង្កើតគណៈកម្មការអន្តរក្រសួង (Commission ad hoc) ទទួលបន្ទុកស្រាវជ្រាវ និងពិនិត្យច្បាប់សមុទ្រ ឆ្នាំ១៩៨២ ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១-តំណាង ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២-តំណាង ក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៣-លោក ឈុន ថុល តំណាងខុទ្ទកាល័យនាយករដ្ឋមន្ត្រី | សមាជិក |
| ៤-តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |